# បឹងចុងក្រោយក្នុងរាជធានីភ្នំពេញ

**ការពិត និងតួលេខ #៤០** **ខែធ្នូ ឆ្នាំ២០១៩**





សមាគមធាងត្នោត

Sahmakum Teang Tnaut • a Cambodian Urban NGO

អង្គការសមាគមធាងត្នោត (STT) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៥ និងត្រូវបានចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជួយគាំទ្រដល់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ នៅឆ្នាំ២០០៦។ អង្គការសមាគមធាងត្នោត ចាប់ផ្តើមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលផ្តោតទៅលើការជួយលើកកម្ពស់ផ្នែកបច្ចេកទេសដល់សហគមន៍ក្រីក្រ និងបន្ទាប់មកចាប់ផ្តើមរីកលូតលាស់ខ្លួនដោយផលិតផែនទីសហគមន៍ក្រីក្រ ការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការជួយដល់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ ឱ្យទទួលបាននូវសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។ អង្គការសមាគមធាងត្នោត សូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមក្នុងកិច្ចស្រាវជ្រាវនេះ ជាពិសេសប្រជាពលរដ្ឋមូលដ្ឋានដែលរស់នៅជុំវិញបឹងទាំងនេះ។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៩៥៥ ១៩ ៦៤

អ៊ីម៉ែល៖ info@teangtnaut.org

គេហទំព័រ: www.teangtnaut.org ហ្វេសប៊ុក: https://www.facebook.com/teangtnaut

Twitter: https://twitter.com/teangtnaut

# មាតិកា


**មាតិកា** i

**១. សេចក្តីផ្តើម** **១**

**២. វិធីសាស្ត្រស្រាវជ្រាវ** **២**

**៣. សាវតា** **៣**

**តើអ្វីទៅជាបឹង? តើអ្វីទៅជាតំបន់ដីសើម?** **៣**

បឹង ៣

តំបន់ដីសើម ៤

តម្លៃនៃបឹង និងតំបន់ដីសើម ៥

សម្រាប់បុគ្គល ៥

សម្រាប់ក្រុមឯកជន ៥

សម្រាប់រាជធានីភ្នំពេញ និងសាធារណៈ ៦

សម្រាប់ពិភពលោក ៦

**៤. ការរកឃើញសំខាន់ៗ** **៧**

បឹង ៧

តំបន់ដីសើម ៧

**បឹងកក់** ១១

ការប្រើប្រាស់ដោយប្រជាពលរដ្ឋ ១២

សារៈសំខាន់ផ្នែកបរិស្ថាន ១២

អនាគតរបស់បឹង ១២

**បឹងតាមោក** ១៤

ការប្រើប្រាស់ដោយប្រជាពលរដ្ឋ ១៥

សារៈសំខាន់ផ្នែកបរិស្ថាន ១៧

អនាគតនៃបឹង ១៧

**តំបន់ដីសើមបឹងទំពុន ឬជើងឯក** **១៩**

ការប្រើប្រាស់ដោយប្រជាពលរដ្ឋ ២០

សារៈសំខាន់ផ្នែកបរិស្ថាន ២១

**៥. សេចក្តីសន្និដ្ឋាន** **២៣**

**៦. អនុសាសន៍** **២៤**



អ្នកនេសាទនៅលើផ្ទៃបឹងតាមោក (ដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

# ១. សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ២០០៣មក ម្ចាស់គម្រោងអភិវឌ្ឍន៍ទីក្រុងរណប និងបុរីជាច្រើនបានចាប់ផ្តើមចាក់ដីខ្សាច់លុបបឹង និងតំបន់ដីសើមក្នុងរាជធានីភ្នំពេញ។ បឹងប្រមាណ៦០ភាគរយ និងតំបន់ដីសើម៤០ភាគរយ ត្រូវបានចាក់លុប។

ជីវភាពប្រជាពលរដ្ឋជាច្រើនដែលពឹងផ្អែកលើបឹង និងដីសើមទាំងនោះកំពុងទទួលរងផលប៉ះពាល់ ដោយប្រជាពលរដ្ឋជាច្រើនពាន់គ្រួសារត្រូវបានគេបណ្តេញចេញពីលំនៅឋាន ឬប្រឈមនឹងការគំរាមកំហែងពីការបណ្តេញចេញនៅថ្ងៃខាងមុខ ខណៈដែលគម្រោងអភិវឌ្ឍន៍នៅបន្តគំរាមកំហែងលំនៅឋាន និងការងាររបស់ប្រជាពលរដ្ឋទាំងនោះ។ ផលប៉ះពាល់ផ្នែកបរិស្ថាននៃនិន្នាការទាំងនេះ នៅមិនទាន់ត្រូវបានគេដឹងច្បាស់លាស់នៅឡើយ ប៉ុន្តែការប៉ាន់ស្មានមួយចំនួនបង្ហាញនូវផលអាក្រក់ធ្ងន់ធ្ងរដែលនឹងកើតមានឡើង ដូចជាទឹកជំនន់ ការបំពុលបរិស្ថាន និងការថមថយនៃទីបង្កកំណើតរបស់មច្ឆាក្នុងបឹងទាំងនោះ។

របាយការណ៍នេះ ផ្តល់នូវទិដ្ឋភាពស្ថានភាពបច្ចុប្បន្ននៃបឹង និងតំបន់ដីសើមធំៗដែលនៅសល់ចុងក្រោយ និងបង្ហាញពីផលវិបាកដែលអាចនឹងកើតមានឡើង ប្រសិនបើបឹង និងតំបន់ដីសើមទាំងនោះ ត្រូវបានបាត់បង់។ របាយការណ៍នេះ រកឃើញថា បឹង និងតំបន់ដីសើមគឺសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ហើយការថែរក្សាតំបន់ទាំងនោះ គួរតែត្រូវបានយកចិត្តទុកដាក់ឱ្យបានល្អ និងអាទិភាពបំផុតដើម្បីឱ្យរាជធានីភ្នំពេញក្លាយទៅជាទីក្រុងដែលមានបរិស្ថានល្អ និងមានការចូលរួមពីគ្រប់ប្រជាពលរដ្ឋ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវដែលបានយកមកប្រើប្រាស់នៅក្នុងរបាយការណ៍នេះ ផ្អែកលើរបាយការណ៍អង្កេត ការសាកសួរ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានជាមួយសហគមន៍ ការសិក្សាលើព័ត៌មាន និងឯកសារពាក់ព័ន្ធដែលមានស្រាប់ ការគូរផែនទី និងវិធីសាស្ត្រលើការវាយតម្លៃពីផលប៉ះពាល់របស់អង្គការសមាគមធាងត្នោត។

ការរកឃើញទាំងអស់មានលក្ខណៈជាក់លាក់ និងកាន់តែត្រឹមត្រូវអាស្រ័យលើព័ត៌មានដែលទទួលបានពីសមាជិកសហគមន៍ និងរូបភាពពីផ្កាយរណប មានន័យថា ពេលខ្លះរូបភាពពីលើអាកាសអាចមិនសុក្រឹត និងគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។

ដើម្បីគណនាចំនួនបឹង នៅក្នុងរាជធានីភ្នំពេញ ការស្រាវជ្រាវនេះបានធ្វើការកំណត់បឹងដែលត្រូវសិក្សាជាក់ស្តែងដោយបានប្រើប្រាស់របាយការណ៍ ស្តីអំពីបឹងពីមុនរបស់អង្គការសមាគមធាងត្នោត។[១] បឹងជាច្រើនផ្សេងទៀតនៅក្នុងរាជធានីភ្នំពេញទំនងជាមិនទាន់ត្រូវបានវាយតម្លៃ ដោយសារទំហំរបស់បឹងទាំងនោះមានលក្ខណៈតូច។

តំបន់ដីសើមដែលត្រូវបានជ្រើសរើសយកមកសិក្សាផ្អែកលើរូបភាពពីផ្កាយរណបក្នុង ឆ្នាំ២០០០ ២០០១ ២០០៣ និង ២០០៦ ដែលមានទំហំសរុបលើសពី ០,៥ គីឡូម៉ែតការ៉េប៉ុណ្ណោះ។

ហេតុដូច្នេះ ទោះបីជាតំបន់ដីសើម និងបឹងមួយចំនួនមិនត្រូវបានបញ្ចូលក្នុងការសិក្សា តែរបាយការណ៍នេះបានស្រាវជ្រាវលើតំបន់ដីសើម និងបឹងធំសំខាន់ៗទាំងអស់នៅក្នុងរាជធានីភ្នំពេញ។

[១] អង្គការសមាគមធាងត្នោត (ឆ្នាំ២០១៥) ការពិត និងតួលេខ#២៨៖ បឹងនៅក្នុងរាជធានីភ្នំពេញ

## ៣. សាវតា

តាំងពីអតីតកាល បឹង និងតំបន់ដីសើមគ្របដណ្តប់មួយភាគធំនៃរាជធានីភ្នំពេញ ដោយសារតែស្ថានភាពដីនៅទីនោះមានរយៈកំពស់ទាប ម៉្យាងវិញទៀត រាជធានីភ្នំពេញស្ថិតនៅតាមច្រាំងទន្លេមេគង្គ និងទន្លេសាប។ រាជធានីភ្នំពេញ ស្ថិតនៅចំកណ្តាលនៃតំបន់ទំនាបលិចទឹក ដែលលាតសន្ធឹងចាប់ពីបឹងទន្លេសាបដល់ដីសណ្តទន្លេមេគង្គនៅភាគខាងត្បូងនៃប្រទេសវៀតណាម។ នៅខណៈដែលរាជធានីភ្នំពេញកាន់តែរីកធំ បឹង និងតំបន់ដីសើមជាច្រើននៅក្បែរនោះ ត្រូវបានលុបដោយសារការចាក់ដីខ្សាច់សម្រាប់សាងសង់អគារ។ បឹង និងតំបន់ដីសើមជាច្រើនបានផ្តល់នូវផលប្រយោជន៍ជាច្រើនផ្នែកសេដ្ឋកិច្ចទៅដល់កសិករ និងអ្នកនេសាទ។

នៅពេលដែលទីក្រុងចាប់ផ្តើមរីកកាន់តែធំ កសិករ និងអ្នកនេសាទទាំងនោះកាន់តែប្រឈមនឹងការគំរាមកំហែងពីម្ចាស់គម្រោងអភិវឌ្ឍន៍ដែលចង់ចាក់ដីលុប និងសាងសង់សំណង់អគារដើម្បីទទួលបានប្រាក់ចំណេញ។ សកម្មភាពទាំងនេះ ពេលខ្លះផ្តល់ផលប៉ះពាល់ដល់សហគមន៍ទាំងមូលនៅក្នុងតំបន់ទាំងនោះ។

### តើអ្វីទៅជាបឹង? តើអ្វីទៅជាតំបន់ដីសើម?

### បឹង

យោងតាមច្បាប់ភូមិបាលកម្ពុជា ឆ្នាំ២០០១ បឹងធម្មជាតិ គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ[២]។ អនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ ឆ្នាំ២០១៥ បានផ្តល់នូវនិយមន័យនៃបឹងនៅក្នុងមាត្រា ៤ ដោយបានលើកឡើងថា បឹង "សំដៅទៅលើផ្ទៃទឹកធំល្វឹងល្វើយកើតពីទីជម្រាល ឬជម្រៅធម្មជាតិ ដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពទឹកមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង"។[៣] និយមន័យនេះពុំបានផ្តល់នូវភាពច្បាស់លាស់ អំពីរបៀបដែលច្បាប់កំណត់ព្រំប្រទល់នៃបឹង ក្នុងករណីដែលវារួមបញ្ចូលទាំងតំបន់ទ្រនាប់ ឬក្នុងករណីដែលវាមានទឹកទៅតាមរដូវកាល។ ច្បាប់នៅមិនទាន់បានកំណត់ឱ្យបានច្បាស់លាស់អំពីបញ្ហានៃការប្រែប្រួលរូបរាង និងស្ថានភាពបឹងនៅឡើយទេ។[៤] ចំពោះបឹងនៅប្រទេសកម្ពុជា ដែលជាប្រទេសទទួលឥទ្ធិពល ពីខ្យល់មូសុង ផ្ទៃបឹងអាចប្រែប្រួលព្រំប្រទល់ជារឿយៗ ទៅតាមរដូវកាល គឺវាអាចកើនឡើងទំហំដោយសារទឹកជំនន់ ឬរលាយបាត់រូបរាងដោយសារគ្រោះរាំងស្ងួត។ ការបញ្ជាក់ឱ្យបានច្បាស់លាស់ថាកន្លែងណាជាបឹង ឬមិនមែនជាបឹង គឺមានសារៈសំខាន់ណាស់ដែលទាក់ទងនឹងច្បាប់ភូមិបាល ព្រោះវានឹងមានឥទ្ធិពលដល់ការកាន់កាប់ជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលរស់នៅតាមមាត់បឹង ក្នុងផ្ទៃបឹង និងតំបន់ជាប់បឹង។

ច្បាប់ភូមិបាល បានបង្ហាញយ៉ាងច្បាស់ថាបឹងធម្មជាតិ គឺជាទ្រព្យសម្បត្តិសាធារណៈ ការទាមទារសិទ្ធិជាម្ចាស់កម្មសិទ្ធិទៅលើបឹងធម្មជាតិ គឺជាការបំពានដោយផ្ទាល់ទៅនឹងច្បាប់[៥] ប៉ុន្តែចំណុចដែលកំណត់ថាត្រង់ណាជាផ្ទៃបឹងគឺនៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយ លុះត្រាតែមានការវាស់វែង និងកំណត់និយាមកាជាផ្លូវការ ។ ករណីបឹងតាមោក ព្រំប្រទល់នៃបឹង ឬផ្ទៃបឹង មានការប្រែប្រួលស្ទើររាល់ខែ ហើយទើបតែនៅ ឆ្នាំ២០១៦

[២] មាត្រា ១៥

[៣] អនុក្រឹត្យលេខ ៩៨ (ឆ្នាំ២០១៥) ស្តីពីការគ្រប់គ្រងអាងទន្លេ មាត្រា ៤

[៤] ដូចខាងលើ មាត្រា ៨

[៥] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៤៣

បឹងនេះត្រូវបានកំណត់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅក្នុងអនុក្រឹត្យ ដោយមានការកំណត់ព្រំប្រទល់ និងនិយាមកាច្បាស់លាស់។[៦]

ដោយសារតែបឹងធម្មជាតិ គឺជាទ្រព្យសម្បត្តិសាធារណៈ ដូចនេះវាជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរទាំងអស់ ហើយត្រូវបានគ្រប់គ្រង និងចាត់ចែងតាមរយៈរាជរដ្ឋាភិបាល។ ការលក់បឹងអាចធ្វើបានលុះត្រាតែបឹងនោះបាត់បង់ការប្រើប្រាស់ជាសាធារណៈរបស់វា។[៧] នៅពេលដែលបឹងមួយត្រូវបានកំណត់ថាបានបាត់បង់ការប្រើប្រាស់ជាសាធារណៈ បឹងអាចត្រូវបានគេកែប្រែពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ បន្ទាប់មកគេលក់ ឬជួលទៅក្រុមមនុស្សដទៃទៀតបាន។[៨]

ព្រះរាជក្រឹត្យលេខ៣៣៩ បានកំណត់នូវបទបញ្ញត្តិ និងនីតិវិធីស្តីពីការធ្វើអនុប្រយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។[៩] ដើម្បីធ្វើចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

១. ទ្រព្យសម្បត្តិនោះមិនមានផលប្រយោជន៍ដល់សាធារណៈ

២. ទ្រព្យសម្បត្តិនោះបានបាត់បង់មុខងារផលប្រយោជន៍សាធារណៈ

៣. ទ្រព្យសម្បត្តិនោះមិនអាចប្រើប្រាស់បានជាសាធារណៈ។[១០]

យោងតាមអនុក្រឹត្យលេខ ១២៩ ដែលបានកំណត់គោលការណ៍ យុទ្ធសាស្រ្ត និងនីតិវិធីសម្រាប់ការរៀបចំ និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ[១១]អាជ្ញាធរដែលមានតួនាទីតាមដាន និងធ្វើរបាយការណ៍ស្តីពីស្ថានភាពនៃការប្រើប្រាស់ជាសាធារណៈនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ គឺជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។[១២]

ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ បឹងនិងតំបន់ដីសើមភាគច្រើននៅតែមានប្រយោជន៍បម្រើដល់សាធារណៈជន ហើយគេនៅតែមិនទាន់ដឹងច្បាស់លាស់ថា តើបឹងទាំងនោះត្រូវបានគេធ្វើអនុប្រយោគ និងដាក់ជួលដោយរបៀបណានោះទេ។

## តំបន់ដីសើម

ច្បាប់ភូមិបាលបានចែងអំពីបឹង តែមិនបានលើកឡើង អំពីតំបន់ដីសើមនោះទេ ទោះជាតំបន់នេះ អាចត្រូវបានគេរាប់បញ្ចូលនៅក្នុងលក្ខខណ្ឌជាតំបន់ ឬទ្រព្យសម្បត្តិសាធារណៈ ដោយយោងតាមមាត្រា ១៥ នៃច្បាប់ដដែលនេះក៏ដោយ។

[៦] អនុក្រឹត្យលេខ ២០ (ឆ្នាំ២០១៦)

[៧] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ១៦

[៨] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ១៧

[៩] ព្រះរាជក្រឹត្យលេខ ៣៣៩ (ឆ្នាំ២០០៦) ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុប្រយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

[១០] ព្រះរាជក្រឹត្យលេខ ៣៣៩ (ឆ្នាំ២០០៦) ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុប្រយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ មាត្រា៣

[១១] អនុក្រឹត្យលេខ ១២៩ ដែលបានកំណត់គោលការណ៍ យុទ្ធសាស្រ្ត និងនីតិវិធីសម្រាប់ការរៀបចំ និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ មាត្រា ១

[១២] ដូចខាងលើ មាត្រា ៤១

កង្វះខាតភាពច្បាស់លាស់នូវការកំណត់ដីសើម បានធ្វើឱ្យកើតមាននូវបញ្ហាក្នុងការការពារតំបន់ដីសើម ដោយសារករណីខ្លះអាចមានការបកស្រាយផ្សេងៗគ្នា ហើយតំបន់ដីសើមខ្លះក៏ត្រូវបានគ្រប់គ្រងដោយកម្មសិទ្ធិឯកជន។ ជាក់ស្តែង តំបន់ដីសើមបឹងទំពុន មិនដែលត្រូវបានវាស់វែងតាមច្បាប់នោះទេ ហើយផ្ទៃបឹងទំពុនដែលត្រូវបានកំណត់ថាជាដីសាធារណៈរបស់រដ្ឋយោងតាមច្បាប់ភូមិបាល ក៏មានទំហំតូចជាងតំបន់ដីសើមបឹងទំពុនទៅទៀត នេះជាអ្វីដែលបានរកឃើញដោយអ្នកស្រាវជ្រាវ។

សម្រាប់គោលបំណងនៃការស្រាវជ្រាវនេះ តំបន់ដីសើមត្រូវបានកំណត់និយមន័យ ដោយយោងតាមអនុសញ្ញារ៉ាមសារ ឆ្នាំ១៩៧១ ដែលបានផ្តល់និយមន័យតំបន់ដីសើមថាជា "តំបន់វាលភក់ វាលទំនាបដែលមានដក់ទឹក ភក់ល្បាប់ ឬទឹក ទោះជាធម្មជាតិ ឬសិប្បនិម្មិត មាននៅជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន មានទឹកនឹង ឬហូរ ទឹកសាប ទឹកភ្លាវ ឬទឹកប្រៃ ដោយរួមទាំងតំបន់ទឹកសមុទ្រដែលមានជម្រៅនៅពេលលំនាច មិនលើសពី ៦ ម៉ែត្រ"។[១៣] អនុសញ្ញារ៉ាមសារស្តីពីតំបន់ដីសើម គឺជាកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិមួយ ដើម្បីបង្កើតតំបន់ដីសើមសម្រាប់ការពារ និងផ្តល់ការប្រឹងប្រែងអភិរក្សតំបន់នោះ។ ប្រទេសកម្ពុជា គឺជាប្រទេសហត្ថលេខីរបស់អនុសញ្ញានេះតាំងពី ឆ្នាំ១៩៩៩[១៤] ហើយបានកំណត់តំបន់ដីសើមចំនួន ៥កន្លែង ជាតំបន់អភិរក្ស ប៉ុន្តែតំបន់ទាំង ៥កន្លែង គឺមិននៅក្នុង ឬក្បែររាជធានីភ្នំពេញនោះទេ។

## តម្លៃនៃបឹង និងតំបន់ដីសើម

បឹង និងតំបន់ដីសើមអាចត្រូវបានផ្តល់តម្លៃទៅតាមរបៀបនៃការប្រើប្រាស់ផ្សេងៗគ្នា។ ខាងក្រោមនេះ យើងនឹងបង្ហាញការវាយតម្លៃបឹងទៅតាមការប្រើប្រាស់ ៤ក្រុមផ្សេងៗគ្នា។

## សម្រាប់បុគ្គល

សម្រាប់បុគ្គល បឹង ឬតំបន់ដីសើមមួយកន្លែងអាចមានតម្លៃសោភ័ណភាព និងផ្តល់ជាកន្លែងសម្រាប់លំហែកាយ ឬធ្វើលំហាត់ប្រាណ។ ការស្រាវជ្រាវថ្មីមួយបានបង្ហាញពីទំនាក់ទំនងរវាងការរស់នៅក្នុងតំបន់ដែលមានពណ៌បៃតងបានធ្វើឱ្យអ្នករស់នៅមានសុខុមាលភាពផ្នែកស្មារតីប្រសើរឡើង។[១៥]

## សម្រាប់ក្រុមឯកជន

ក្រុមឯកជន បឹង ឬតំបន់ដីសើមមួយកន្លែងអាចបង្កើនតម្លៃដល់អចលនទ្រព្យ តាមរយៈការបង្កើតឱ្យមានសោភ័ណភាពទ្រព្យដែលនៅក្បែរនោះកាន់តែស្រស់ស្អាតដល់ការរស់នៅ និងធ្វើអាជីវកម្ម។ មានការសិក្សាស្រាវជ្រាវមួយ បានបង្ហាញថាអចលនទ្រព្យអាចបង្កើនតម្លៃពី ៨ ទៅ ១២ ភាគរយ ប្រសិនបើអចលនទ្រព្យនៅជិតបឹងហើយអាចមើលឃើញទេសភាពបឹងទៀត នោះតម្លៃនឹងអាចឡើងដល់ ២៨ ភាគរយ។[១៦]

---

[១៣] អនុសញ្ញារ៉ាមសារស្តីពីតំបន់ដីសើម (ឆ្នាំ១៩៧១) មាត្រា ១

[១៤] "ភាគីនៃអនុសញ្ញាស្តីពីតំបន់ដីសើម" អនុសញ្ញាស្តីពីតំបន់ដីសើម បច្ចុប្បន្នភាពចុងក្រោយថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣

[១៥] Gascon et al, (ឆ្នាំ២០១៧), "ទីធ្លាខាងក្រៅដែលមានពណ៌ខៀវ សុខភាព និងសុខុមាលភាពមនុស្ស៖ ការពិនិត្យឡើងវិញជាប្រព័ន្ធមួយនៃសិក្សាបែបបរិមាណ"ទន្និនុប្បវត្តិអន្តរជាតិ ស្តីពីអនាម័យ និងបរិស្ថានសុខភាព ២២០ ទំ.១២០៧-១២២១។

[១៦] Luttik, J, (ឆ្នាំ២០០០) "តម្លៃនៃដើមឈើ ទឹក និងទីធ្លា ពាក់ព័ន្ធនឹងតម្លៃនៃផ្ទះសម្បែងនៅប្រទេសហូឡង់" ផែនការទេសភាព និងទីប្រជុំជន ៤៨ ទំ.១៦១-១៦៧; ក៏សូមមើល Nicholls, S & J Crompton, (ឆ្នាំ២០១៧), "ផលប៉ះពាល់នៃទន្លេ អូ និងព្រែក ទៅលើតម្លៃអចលនទ្រព្យ" River Res Applic. ១៣៧៧-១៣៨៦

## សម្រាប់រាជធានីភ្នំពេញ និងសាធារណៈ

សម្រាប់សាធារណៈ តំបន់ដីសើម និងបឹងអាចជួយបញ្ចៀសពីការលិចលង់ដោយទឹកជំនន់ ដោយអាចស្រូបយកទឹកក្នុងចំនួនយ៉ាងច្រើន ហើយបង្ហូរចេញវិញដោយល្បឿនយឺត។ បឹង និងដីសើមទាំងនោះក៏អាចផ្តល់នូវភាពត្រជាក់ដល់តំបន់នៅជុំវិញនោះ ដែលធ្វើឱ្យទីក្រុងមិនសូវឡើងកំដៅ និងកាត់បន្ថយកំដៅដែលកើតឡើងពីអាគារខ្ពស់ៗជាច្រើន។[១៧]

លើសពីនេះ បឹងនានា និងតំបន់ដីសើម ផ្តល់ប្រយោជន៍សេដ្ឋកិច្ច តាមរយៈការដាំដំណាំលើទឹក ចាប់កង្កែប រកខ្យងខ្ចៅ ការនេសាទត្រី និងទេសចរណ៍។ ទេសចរណ៍បៃតងអាចគាំទ្រដល់អាជីវកម្មក្នុងតំបន់ប្រសិនបើបឹង និងតំបន់ដីសើមទាំងនោះត្រូវបានថែក្សា។

លើសពីនេះ តំបន់ដីសើម និងបឹងដែលមានតម្លៃមួយចំនួន ដូចជាបឹងទំពុន ឬជើងឯក ត្រូវបានប្រើប្រាស់ជាមណ្ឌលប្រព្រឹត្តកម្មទឹកកខ្វក់ ដូចជាទឹកលូ ទឹកដែលមានជាតិគីមី តាមរយៈវិធីសាស្ត្រធម្មជាតិ ដែលអាចសម្អាតទឹកដែលមានជាតិពុល និងកាត់បន្ថយគ្រោះថ្នាក់ដល់បរិស្ថាន និងសង្គម។ ដូចនេះ វាអាចជួយសន្សំថវិកាបានយ៉ាងច្រើន ដោយបង្កើតឱ្យមានវិធីសាស្ត្រប្រព្រឹត្តកម្មទឹកស្អាតដែលមានតម្លៃទាប ខណៈពេលដែលការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ដោយស្ថានីយចម្រោះ គឺមានតម្លៃថ្លៃ។

## សម្រាប់ពិភពលោក

បឹង និងតំបន់ដីសើមជាច្រើន គឺមានតម្លៃមិនអាចកាត់ថ្លៃបាន សម្រាប់សុខភាពមនុស្សទូទៅក្នុងពិភពលោក។ បឹង និងតំបន់ដីសើមទឹកសាប ដូចជាបឹង និងតំបន់ដីសើមដែលនៅជុំវិញរាជធានីភ្នំពេញ គឺជាប្រភពសម្រាប់ទឹកផឹកដ៏សំខាន់មួយ ហើយក៏មានឥទ្ធិពលដល់គុណភាពខ្យល់ តាមរយៈរុក្ខជាតិដែលដុះក្នុងនិងលើទឹកដែលអាចកាត់បន្ថយនូវជាតិគីមីពុលមួយចំនួនដូចជាការស្រូបយកឧស្ម័នកាបូនិចហើយបញ្ចេញមកវិញ នូវឧស្ម័នអុកស៊ីសែន ដើម្បីបន្សុទ្ធខ្យល់នៅក្នុងបរិយាកាស និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើភពផែនដី។

[១៧] Gupta, N, A, Mathew, និង S, Khandelwal, (ឆ្នាំ២០១៩) "ការវិភាគនៃឥទ្ធិពលធ្វើឲ្យត្រជាក់នៃទឹក សីតុណ្ហភាពលើផ្ទៃដីនៅតំបន់ក្បែរខាង" ទិនានុប្បវត្តិប្រទេសអេស៊ីបនៃញាណពីចង្វាយ និងវិទ្យាសាស្ត្រទីធ្លា ២២ (១) ៨១-៩៣

## ៤. ការរកឃើញសំខាន់ៗ

បឹង និងតំបន់ដីសើមក្នុងរាជធានីភ្នំពេញ ជិតត្រូវបានបាត់បង់ទាំងស្រុង។ ប្រសិនបើស្ថានភាពនេះ នៅតែបន្តដូចការស្មានទុក ទីក្រុង និងតំបន់នៅជុំវិញអាចនឹងត្រូវរងគ្រោះពីទឹកជំនន់ធ្ងន់ធ្ងរ ការបាត់បង់ពូជត្រី ការបាត់បង់អាងប្រព្រឹត្តកម្មទឹកកខ្វក់បែបធម្មជាតិ និងការបាត់បង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

### បឹង

ចាប់តាំងពី ឆ្នាំ១៩៩០មក ក្នុងចំនោមបឹងចំនួន២៦ នៅក្នុងរាជធានីភ្នំពេញ[១៨] មានបឹងចំនួន១៦ ត្រូវបានចាក់ដីលុបបំពេញ និងបឹងចំនួន១០ទៀត ត្រូវបានចាក់ដីលុបខ្លះៗរួចហើយ។ ពុំមានបឹងដែលត្រូវបានសិក្សាណាមួយ នៅមិនទាន់ត្រូវបានមនុស្សប៉ះពាល់នោះទេ ចាប់តាំងពីឆ្នាំ១៩៩០ មក។ មូលហេតុចម្បងនៃការបាត់បង់បឹងទាំងនោះ បណ្តាលមកពីការសាងសង់បុរី តំបន់លំនៅឋាន និងទីក្រុងរណប។

### តំបន់ដីសើម

មិនខុសគ្នាពីបឹងនៅក្នុងរាជធានីភ្នំពេញ តំបន់ដីសើម ក៏ទទួលរងការបាត់បងយ៉ាងធ្ងន់ធ្ងរដែរ។ ចន្លោះពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០១៩ តំបន់ដីសើមសំខាន់ៗជាង ៤០ភាគរយ ត្រូវបានបាត់បង់ដោយសារការចាក់ដីលុបបំពេញ ឬតាមរយៈការធ្វើអនុប្រយោគ និងការជួល។

ទីក្រុងរណបជាច្រើនគឺជាមូលហេតុចម្បងដែលបណ្តាលឱ្យមានការបាត់បង់តំបន់ដីសើមទាំងនោះ។

[១៨] របាយការណ៍របស់អង្គការសមាគមធាងត្នោតឆ្នាំ២០១៥ ការពិត និងតួលេខ #២៨ ៖ បឹងនៅក្នុងរាជធានីភ្នំពេញ

| តារាងទី ១៖ ស្ថានភាពបឹងក្នុងរាជធានីភ្នំពេញឆ្នាំ ២០១៩ | | | | |
|---|---|---|---|---|
| **ល.រ** | **ឈ្មោះបឹង** | **ស្ថានភាព** | **ការប្រើប្រាស់បច្ចុប្បន្ន** | **ទីតាំង(ខណ្ឌ)** |
| ១ | បឹងត្របែក ១ | លុបទាំងស្រុង | តំបន់លំនៅឋាន/ ផ្សេងៗ | ចំការមន |
| ២ | បឹងត្របែក ២ | លុបមួយផ្នែក | តំបន់លំនៅឋាន | ចំការមន |
| ៣ | បឹងទំពុន ១ | លុបមួយផ្នែក | តំបន់លំនៅឋាន | មានជ័យ |
| ៤ | បឹងទំពុន ២ | លុបមួយផ្នែក (កំពុងលុប) | ក្រុមហ៊ុន អាយអិនជី ស៊ីធី (ទីក្រុងរណប) | មានជ័យ |
| ៥ | បឹងជើងឯក | លុបមួយផ្នែក (កំពុងលុប) | ក្រុមហ៊ុន អាយអិនជី ស៊ីធី (ទីក្រុងរណប) | ដង្កោ និងមានជ័យ |
| ៦ | បឹងតាម៉ាត | លុបទាំងស្រុង | ចាក់លុបដើម្បីសង់លំនៅឋាន | ដង្កោ |
| ៧ | បឹងស្នោរ | លុបទាំងស្រុង | រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់ និរោធ/ លំនៅឋាន/ ផ្សេងៗ | ច្បារអំពៅ |
| ៨ | បឹងឈូក | លុបទាំងស្រុង | បុរី ប៉េង ហួត | ច្បារអំពៅ |
| ៩ | បឹងសាឡាង | លុបទាំងស្រុង | តំបន់លំនៅឋាន | ទួលគោក |
| ១០ | ប្រឡាយលូ ៥ | លុបទាំងស្រុង | បុរី ជ័យជំនះ និងបុរី វិមាន ភ្នំពេញ | មានជ័យ |
| ១១ | ត្រពាំងឈូក | លុបទាំងស្រុង | បុរី និងតំបន់លំនៅឋាន | សែនសុខ |
| ១២ | បឹងទួលពពៃ | លុបទាំងស្រុង | បុរី ពិភពថ្មី | ដង្កោ |
| ១៣ | បឹងតាមោក ឬ បឹងកប់ស្រូវ | លុបខ្លះៗ/ មិនមានផែនការច្បាស់លាស់ | ការរំលោភយក/ ការនេសាទ/ ការចាក់ដីសម្រាប់សាងសង់ផ្សារ | ព្រែកព្នៅ |
| ១៤ | បឹងរាជសីហ៍ | លុបទាំងស្រុង | ហ្គ្រេនភ្នំពេញ អ៊ិនធើណេសិនណល ស៊ីធី (ទីក្រុងរណប) | សែនសុខ |
| ១៥ | បឹងចំរើ្មក្រពើ | លុបទាំងស្រុង | តំបន់ទំនេរ និងលិចទឹកនៅពេលភ្លៀង | សែនសុខ |
| ១៦ | បឹងខាំពង | លុបមួយផ្នែក | អរគីដេ វីឡា (ទីក្រុងរណប) | ជ្រោយចង្វារ |
| ១៧ | បឹងឈូក | លុបទាំងស្រុង | បុរី អង្គរ ភ្នំពេញ | ឫស្សីកែវ |
| ១៨ | បឹងប៉ាយ៉ាប | លុបមួយផ្នែក | បុរី ពិភពថ្មី បុរី សែនសុខ បុរី ប៉េងហួត កាំកូ ស៊ីធី និងផ្សេងៗ | ឫស្សីកែវនិងសែនសុខ |
| ១៩ | បឹងពោងពាយ | លុបទាំងស្រុង | បុរី ពិភពថ្មី បុរី សែនសុខ បុរី ប៉េងហួត ឌីស្តារឡាយ និងផ្សេងៗ | សែនសុខ |
| ២០ | បឹងអូរអង្គាម | លុបទាំងស្រុង | រោងចក្រក្រុមហ៊ុន វិនខេម (WINCAM) និងផ្សេងៗ | ឫស្សីកែវ |
| ២១ | បឹងកក់ | លុបទាំងស្រុង | ក្រុមហ៊ុន ស៊ូកាគូ (ទីក្រុងរណប) | ទួលគោក |
| ២២ | បឹងសាឡាង | លុបទាំងស្រុង | បុរី សុភមង្គល បុរី វិទ្ធី បុរី ទួលសង្កែ បុរី ណៃសុវណ្ណ បុរី សម្បត្តិមាស | ឫស្សីកែវ |
| ២៣ | បឹងទទឹងថ្ងៃ | លុបទាំងស្រុង | ទីក្រុង រណប អូស៊ីអាយស៊ី (មិនទាន់ដឹងច្បាស់ពីឈ្មោះទីក្រុងរណប) | ជ្រោយចង្វារ |
| ២៤ | បឹងឈូក | លុបមួយផ្នែក | តំបន់លំនៅឋាន | ឫស្សីកែវ |
| ២៥ | បឹងក្បាលដំរី | លុបមួយផ្នែក | បុរី ឡាយគង់ និង ហ្គ្រេនភ្នំពេញ អ៊ិនធើណេសិនណល ស៊ីធី (តំបន់វាយកូនហ្គោល) និងផ្សេងៗ | សែនសុខ |
| ២៦ | បឹងសំរោង | លុបមួយផ្នែក/ អភិរក្ស | ការរំលោភយក ការនេសាទ ឬការចាក់ដីលុបដោយក្រុមហ៊ុន ឡាយជី | ព្រែកព្នៅ |
| **សរុប** | | **បឹងចំនួន ១៦ ត្រូវបានចាក់ដីលុបទាំងស្រុង ហើយ ១០ ត្រូវបានចាក់លុបខ្លះៗ។ គ្មានបឹងណាមួយ ដែលមិនត្រូវបានគេប៉ះពាល់នោះទេ។** | | |

| តារាងទី ២៖ តំបន់ដីសើមក្នុងរាជធានីភ្នំពេញឆ្នាំ ២០១៩ | | | | | |
|---|---|---|---|---|---|
| ល.រ | តំបន់ដីសើម | ២០០៣ (គម²) | ២០១២/១៣ | ២០១៨ | មូលហេតុនៃការផ្លាស់ប្តូរ |
| ១ | ជ្រោយចង្វារខាងជើង | ២១,៥ | ១៥,១៩ | ១៤,៦៧ | ទីក្រុងរណប (ទីក្រុង អរគីដេហ្គាឌិន) |
| ២ | បឹងរាជសីហ៍ | ៥,៤៨ | ២ | ០,៧៨ | ទីក្រុងរណប (ហ្គ្រេនភ្នំពេញ បុរីប៉េងហួត) |
| ៣ | ទំពុន/ជើងឯក | ១៤,៩ | ១៤,៩ | (២០១៩)១,៧ ត្រូវបានវាស់វែងស្របច្បាប់ | ទីក្រុងរណប (ក្រុមហ៊ុន អាយអិនជី) |
| ៤ | បឹងតាមោក | ៣១,៦ | ២៥,៣ | ៣១,៩ ត្រូវបានវាស់វែងស្របច្បាប់ | បន្ថែមជម្រៅបឹង/ ការរំលោភតិចតួច/ ចាក់ដីលុបសាងសង់ផ្សារ/ រួមតូចដោយធម្មជាតិ |
| ៥ | បឹងសំរោង | ៥,១៥ | ៣,១៩ | ២,៨ | ចាក់ខ្សាច់លុប/ បែរចិញ្ចឹមត្រីឬនេសាទ |
| ៦ | ច្បារអំពៅ | ១០,៨ | ៩,០៨ | ៥,៨៤ | បុរី ប៉េងហួត ទីស្តារផ្លាទីនីម រូសាតូ |
| ៧ | ព្រែកធំ | ៥,៥២ | ៦,០១ | ១,៤៣ | ទីលានវាយកូនហ្គោល វត្តឬនៈ |
| ៨ | ទំពុន | ០,៥៤២ | ០,៣៨៦ | ០,៣៣៣ | តំបន់លំនៅឋាន |
| ៩ | បឹងកក់ | ០,៩៧៥ | ០,០១២ | ០,០ | ក្រុងរណប ស៊ូកាគូ |
| ១០ | សែនសុខ | ៣,១៣ | ១,៨ | ០,១១៨ | បុរី ប៉េងហួត កាំកូស៊ីធី អេអនម៉ល ទី២ |
| ១១ | ជ្រោយចង្វារខាងត្បូង | ១,៥ | ១,១៥ | ០,១៧ | ទីក្រុងរណប (គម្រោង អូស៊ីអាយស៊ី) |
| | **សរុប** | ១០១ | ៧៩ | ៥៩,៧ | **បាត់បង់ជាង ៤០ ភាគរយនៃតំបន់ដីសើម** |

| តារាងទី ៣៖ ចំនួនសរុបនៃបឹង និងតំបន់ដីសើមក្នុងរាជធានីភ្នំពេញដែលបានបាត់បង់ | | |
|---|---|---|
| តំបន់ | ការបាត់បង់ (ជាភាគរយ) | មូលហេតុចំបងនៃការបាត់បង់ |
| បឹង | បឹងទាំង២៦ ត្រូវរងផលប៉ះពាល់ ហើយក្នុងនោះមានចំនួន១៦ (៦០%) ត្រូវបានចាក់ដីលុប។ | បុរី តំបន់លំនៅឋាន និងទីក្រុងរណប |
| តំបន់ដីសើម | ការបាត់បង់ (ឬការបាត់បង់ដែលត្រូវបានគេប៉ាន់ស្មាន) ប្រមាណ ៤១,៣ គម² (៤១%) នៃតំបន់ដីសើមសំខាន់ៗ។ | ទីក្រុងរណប |


តំបន់ដីសើម ឆ្នាំ២០០៣
Khsach Kandal
ខ្សាច់កណ្ដាល
Koh Dach
Sre Ampil
ស្រែអំពិល
Prey Svay
ព្រៃស្វាយ
Brasath
ប្រាសាទ
Thmor
ថ្ម
Phnom Penh
រាជធានីភ្នំពេញ
Lvea Aem
ល្វាឯម
Kien Svay
កៀនស្វាយ
Angk Snuol
អង្គស្នួល
Thnal Totueng
ថ្នល់ទទឹង
KANDAL PROVINCE
PHNOM PENH
PREY VENG PROVINCE
Baku
ភូមិបាគូ
Krong Ta Khmau
ក្រុងតាខ្មៅ
Prek
ព្រែក
Chen
ចិន
Siem Reap
សៀមរាប


តំបន់ដីសើម ឆ្នាំ២០១៨/១៩
Koh Dach
Sre Ampil
ស្រែអំពិល
Prey Svay
Brasath
ប្រាសាទ
Thmor
ថ្ម
Phnom Penh
រាជធានីភ្នំពេញ
Lvea Aem
ល្វាឯម
Kien Svay
កៀនស្វាយ
Angk Snuol
អង្គស្នួល
Thnal Totueng
ថ្នល់ទទឹង
KANDAL PROVINCE
PHNOM PENH
PREY VENG PROVINCE
Baku
ភូមិបាគូ
Krong Ta Khmau
ក្រុងតាខ្មៅ
Prek
ព្រែក
Chen
ចិន

**បឹងកក់**

**ផ្ទៃបឹង៖** ៩០ ហិចតា (ត្រូវបានវាស់វែងស្របច្បាប់) លែងជាបឹងចាប់ពីឆ្នាំ ២០១៣

**ប្រជាពលរដ្ឋ (ប្រឈមនឹងការបណ្តេញចេញ ឬបាត់បង់របរចិញ្ចឹមជីវិត)** ៖ ៤,២៥៣ គ្រួសារ ត្រូវបានបណ្តេញចេញ

**សារៈសំខាន់ផ្នែកបរិស្ថាន៖** ការពារទឹកជំនន់ និងផ្តល់តំបន់ពណ៌បៃតង




ស្ទើរតែទាំងអស់នៃតំបន់បឹងកក់ មិនមានការតាំងលំនៅឋាននោះទេ រហូតដល់ឆ្នាំ ១៩៨៨។ ប្រជាពលរដ្ឋជាច្រើនគ្រួសារចាប់ផ្តើមសាងសង់លំនៅឋាននៅតំបន់នោះ នៅអំឡុង ឆ្នាំ១៩៩៣ ហើយប្រជាពលរដ្ឋនៅទីនោះប្រកបរបរដាំដំណាំលើផ្ទៃទឹក។ នៅឆ្នាំ២០០៧ រាជរដ្ឋាភិបាលកម្ពុជា បានដាក់តំបន់នោះជួលរយៈពេល ៩៩ឆ្នាំ ឱ្យទៅក្រុមហ៊ុន ស៊ូកាគូ ក្នុងទឹកប្រាក់ចំនួន៧៩ លានដុល្លារអាមេរិក ហើយការចាក់ដីខ្សាច់លុប ចាប់ផ្តើមនៅឆ្នាំ ២០០៨។[១៩] បឹងកក់ត្រូវបានចាក់ដីលុបពេញនៅឆ្នាំ២០១៣។

[១៩] ម៉ៃ ទិត្យថារ៉ា (ឆ្នាំ២០១០).ប្រជាពលរដ្ឋបឹងកក់ស្វែងរកការអន្តរាគមន៍ពីសាលាក្រុងក្នុងករណីវិវាទដីធ្លី, ការសែតភ្នំពេញប៉ុស្តិ៍ថ្ងៃទី១១ ខែមិនា ឆ្នាំ២០១០ ប្រភព៖ <http://www.phnompenhpost.com/national/boeung-kak-villagers-call-pm-intervene-land-case>

## ការប្រើប្រាស់ដោយប្រជាពលរដ្ឋ

ប្រជាពលរដ្ឋចំនួន៤,២៥២គ្រួសារ បានរស់នៅជុំវិញបឹងកក់ហើយភាគច្រើននៃប្រជាពលរដ្ឋទាំងនោះអាស្រ័យផលដោយសារបឹង ដើម្បីរកប្រាក់ចំណូល។ សមាជិកសហគមន៍ជាច្រើន គឺជាជនភៀសខ្លួន ដែលទើបត្រឡប់មកពីប្រទេសថៃ ដែលបានភៀសខ្លួនអំឡុងពេលរបបប៉ុលពត។ ជាធម្មតានៅក្នុងរាជធានីភ្នំពេញ សហគមន៍ក្រីក្រតែងតែបង្ខំចិត្តស្វែងរកទីជម្រក ដោយហេតុថា បច្ចុប្បន្ននេះមិនមានជំនួយឧបត្ថម្ភពីរដ្ឋ ដើម្បីផ្គត់ផ្គង់ផ្ទះដែលមានតម្លៃសមរម្យដល់ប្រជាពលរដ្ឋក្រីក្រ។

ការចាក់ដីលុបបឹងធ្វើឱ្យខូចខាត និងលិចលង់ដល់ផ្ទះសម្បែងជាច្រើនខ្នង ហើយធ្វើឱ្យប្រជាពលរដ្ឋជាច្រើនគ្រួសារបង្ខំចិត្តចាកចេញពីទីតាំងនោះ និងដោយមិនមានសំណងសមរម្យ។ អំពើហិង្សា និងការគំរាមគំហែងត្រូវបានប្រើប្រាស់ទៅលើប្រជាពលរដ្ឋក្នុងតំបន់បឹងកក់ដែលតវ៉ាប្រឆាំងនឹងការបណ្តេញចេញពីលំនៅឋានរបស់ពួកគេ។ នៅក្នុង ឆ្នាំ២០១០ ប្រជាពលរដ្ឋជាង២០០០ គ្រួសារត្រូវបានគេបង្ខំឱ្យទទួលសំណងដែលមានតម្លៃទាបជាងទីផ្សារ។

## សារៈសំខាន់ផ្នែកបរិស្ថាន

ដោយសារតែពាក់ព័ន្ធនឹងផលប៉ះពាល់ពីទឹកជំនន់សារៈសំខាន់ផ្នែកបរិស្ថាននៃតំបន់បឹងកក់ ត្រូវបានគេវាយតម្លៃយ៉ាងឯករាជ្យនៅក្នុងរបាយការណ៍វាយតម្លៃទឹកជំនន់មួយ ដែលត្រូវបានធ្វើឡើងដោយក្រុមអ្នកជំនាញអន្តរជាតិកាលពី ឆ្នាំ២០០៨។[២០] របាយការណ៍នេះបានលើកឡើងថា គម្រោងនេះអាច "ផ្តល់ផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់ទ្រព្យសម្បត្តិ និងបង្កគ្រោះថ្នាក់ដល់ជីវិតនៅតំបន់ទំនាបខាងក្រោម"[២១]។ លើសពីនេះ របាយការណ៍នេះមិនស្របទៅនឹងផែនការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបង្ហូរទឹក ដែលបង្ហាញនៅក្នុងរបាយការណ៍វាយតម្លៃពីផលប៉ះពាល់សង្គម និងបរិស្ថានរបស់ក្រុមហ៊ុន ស៊ូកាគូនោះទេ។ របាយការណ៍ដដែលបានកត់សម្គាល់ថា ការសាងសង់ប្រព័ន្ធបង្ហូរទឹក ដោយសាលារាជធានីភ្នំពេញ(MPP) គឺមានទំហំតូច។[២២] របាយការណ៍នោះ បានសន្និដ្ឋានថា ការចាក់ដីលុបបឹងនឹងបង្កើនកម្រិតទឹកជំនន់ធ្ងន់ធ្ងរ និងញឹកញាប់ហើយវាបានពណ៌នាផលប៉ះពាល់ទាំងនោះថាជា "ហានិភ័យសម្រាប់សុខភាពសាធារណៈ"[២៣]។

## អនាគតរបស់បឹង

គិតត្រឹមពាក់កណ្តាលឆ្នាំ ២០១៩ ទីក្រុងរណប ស៊ូកាគូ នៅបន្តសាងសង់នៅឡើយ។

---

[២០] Benham, S និង B Caddis, (ឆ្នាំ២០០៨), ការវាយតម្លៃ ពីប្រព័ន្ធបង្ហូរទឹក និងទឹកជំនន់នៃតំបន់បឹងកក់

[២១] ដូចខាងលើ

[២២] ដូចខាងលើ

[២៣] ដូចខាងលើ



បឹងតាមោក និងអាគារខ្ពស់ៗនៅក្នុងរាជធានីភ្នំពេញ  (ដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

**បឹងតាមោក**

**ផ្ទៃបឹង៖** ៣,២៣៩ ហិចតា (តំបន់ដែលត្រូវបានវាស់វែងស្របច្បាប់)

**ចំនួនប្រជាជន (ប្រឈមនឹងការបណ្តេញចេញ/បាត់បង់ជីវភាពរស់នៅ)៖** >៣១៩ គ្រួសារ

***សារៈសំខាន់ផ្នែកបរិស្ថាន៖*** ការការពារទឹកជំនន់ អាងស្តុកទឹកស្អាតមានលក្ខណៈធម្មជាតិ ធនធានត្រី និងបក្សីនៅក្នុងតំបន់នោះ។




បឹងតាមោក ឬបឹងទំនប់កប់ស្រូវ គឺជាបឹងដែលធំជាងគេបំផុតនៅក្នុងរាជធានីភ្នំពេញ។ បឹងនេះ មានទីតាំងនៅភាគពាយព្យនៃរាជធានីភ្នំពេញ និងស្ថិតក្នុង ៥សង្កាត់។ បឹងនេះត្រូវបានគេប្រើប្រាស់តាំងពីអតីតកាលសម្រាប់ស្រោចស្រពដំណាំស្រូវ និងការនេសាទ។

កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យលេខ ២០ ដែលបានដាក់បឹងនេះ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដោយគ្របដណ្តប់ទៅលើផ្ទៃដីចំនួន ៣,២៣៩ ហិចតា។ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ អាជ្ញាធរសង្កាត់ព្រែកព្នៅ បានចេញនូវលិខិតមួយច្បាប់ទៅប្រជាពលរដ្ឋមួយចំនួនដែលរស់នៅ និងនេសាទនៅលើផ្ទៃបឹង ដោយឱ្យអ្នកទាំងនោះចាកចេញពីតំបន់នោះក្នុងរយៈពេល ៧ថ្ងៃ។ ប្រជាពលរដ្ឋមួយចំនួនទៀត មិនទាន់ទទួលបានលិខិតនោះទេ ប៉ុន្តែបានទទួលដំណឹងមិនផ្លូវការថា ពួកគេកំពុងកាន់កាប់ដីរបស់រដ្ឋ។ មិនមានវេទិកាសាធារណៈត្រូវបានធ្វើឡើង ដើម្បីពិភាក្សាអំពីផែនការសម្រាប់បឹងនោះទេ។

## ការប្រើប្រាស់ដោយប្រជាពលរដ្ឋ

បឹងតាមោក មានប្រជាពលរដ្ឋ ៣១៩គ្រួសារ កំពុងរស់នៅ ដែលភាគច្រើនរស់នៅក្នុងព្រំប្រទល់នៃបឹង ឬរស់នៅតាមព្រំប្រទល់បឹង។ ក្នុងចំណោមគ្រួសារទាំងនោះ ភាគច្រើនជាអ្នកនេសាទ និងស្រ្តីដែលប្រកបរបរដាំដំណាំលើផ្ទៃបឹង និងបោកគក់ខោអាវ លាងចាន ហើយនិងប្រើប្រាស់បឹងសម្រាប់ធ្វើជាបន្ទន់អនាម័យផងដែរ។ មិនមានគ្រួសារណាមួយដែលត្រូវបានសម្ភាសដោយអង្គការសមាគមធាងត្នោត មានប្លង់កម្មសិទ្ធិដីធ្លីនោះទេ ដែលធ្វើឱ្យពួកគេងាយរងគ្រោះពីការបណ្តេញចេញដោយបង្ខំ។

ដោយផ្អែកទៅលើទំហំរបស់បឹង បឹងតាមោកបានផ្តល់នូវឱកាសសម្រាប់ការនេសាទ។ ជាលទ្ធផលសហគមន៍មួយចំនួនបានចូលមកតំបន់បឹងតាមោកនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីប្រកបរបរនេសាទនៅលើផ្ទៃបឹងនេះ។ ការសម្របតាមវប្បធម៌ខុសៗគ្នានៃការនេសាទបានបន្តកើតមានឡើងនៅលើផ្ទៃបឹងដែលបង្កើតជាទិដ្ឋភាពដ៏ស្អាតនៃវិធីសាស្រ្តក្នុងការនេសាទខ្នាតតូច ដូចជាការនេសាទលក្ខណៈគ្រួសារ ការដាក់មងត្រី និងការដាក់លបត្រី។ តារាងខាងក្រោម ផ្តល់នូវព័ត៌មានស្តីពី ចំណូលពីការនេសាទរបស់គ្រួសារដែលរស់នៅលើផ្ទៃបឹង៖

| **ប្រភេទត្រី** | **តម្លៃក្នុងមួយគីឡូក្រាម** |
|---|---|
| ត្រីនុយ | ២.០០០ រៀល |
| ត្រីទីឡាបយ៉ា | ៤.០០០ រៀល |
| កំពឹស | ១០.០០០ រៀល |

ប្រជាពលរដ្ឋរាប់រយគ្រួសារ ពឹងផ្អែកលើបឹងដើម្បីរកអាហារ និងប្រាក់ចំណូល។ ក្រៅពីត្រី ក៏មានរុក្ខជាតិ និងសត្វមួយចំនួនដែលដុះ និងរស់នៅក្នុងផ្ទៃបឹង ដូចជាត្រកួន មើមឈូក ផ្លែឈូក ខ្យង និងកង្កែប។ អាហារទាំងនេះ អាចជួយកាត់បន្ថយការចំណាយរបស់គ្រួសារក្រីក្រជាច្រើន និងបង្កើនអាហារូបត្ថម្ភ និងសុវត្ថិភាពផ្នែកចំណីអាហារ។



**រូបភាពទី១៖** ការចិញ្ចឹមត្រីសម្រាប់លក់នៅទីផ្សារនៅពេលត្រីធំ។



**រូបភាពទី២៖** ការបង់សំណាញ់ចាប់ត្រី។ សំណាញ់ត្រូវបានបោះពីទីខ្ពស់ ដើម្បីចាប់ត្រីតូចៗ។



**រូបភាពទី៣៖** អន្ទាក់រាងជាព្រួញ ដែលធ្វើឱ្យត្រីជាប់ក្នុងសំណាញ់នៅខាងចុង។ ត្រីអាចចូលក្នុងអន្ទាក់យ៉ាងស្រួលតែមិនអាចចេញវិញបាន ដោយសារភាពប៉ិនប្រសប់នៃការរៀបចំរន្ធចូល ឬចេញ។



**រូបភាពទី៤៖** អន្ទាក់ចាប់ត្រីធ្វើពីឈើងាប់និងមែកឈើធំៗ សម្រាប់ផ្តល់កន្លែងលាក់ខ្លួនឱ្យត្រី បន្ទាប់មកអ្នកនេសាទដាក់សំណាញ់នៅជុំវិញ ហើយឱ្យត្រីចេញពីគុម្ពឈើនោះដោយប្រើសំទ្បេង និងឈើវែងៗ។



**រូបភាពទី៥៖** សំណាញ់ធំមួយនៅមុខកាណូត ត្រូវបានគេទំលាក់ចូលផ្ទៃបឹង រួចលើកមកវិញដើម្បីចាប់ត្រី។



**រូបភាពទី៦៖** ការប្រមូលផលផ្លែឈូក មើមឈូក និងគ្រាប់ឈូកដែលដុះដោយធម្មជាតិនៅក្នុងផ្ទៃបឹង។

## សារៈសំខាន់ផ្នែកបរិស្ថាន

បឹងតាមោកគឺជាអ្នកការពារទឹកជំនន់ ទប់ទល់នឹងលំហូរទឹកមកពីភាគខាងជើង។ ទំនប់បឹងតាមោកជួយបង្វែរលំហូរទឹកពីភាគខាងជើងឱ្យទៅភាគខាងកើតវិញ ឬរក្សាផ្ទុកទឹកក្នុងទំហំធំ។ ទំនប់ដែលលាតសន្ធឹងពីកើតទៅលិចតាមបណ្តោយភាគខាងត្បូងនៃបឹង បង្ការទឹកជំនន់មកពីខាងជើងបានយ៉ាងមានប្រសិទ្ធភាពដោយមិនឱ្យហូរចូលមកទីក្រុងហើយជន់លិចមួយផ្នែកធំនៃទីក្រុង។ (សូមមើលរូបភាពទី ៨ ខាងក្រោម)

## អនាគតនៃបឹង

គម្រោងសម្រាប់បឹងតាមោក នៅមានភាពស្រពេចស្រពិល។ នៅលើខ្នងទំនប់នៃបឹង ត្រូវបានអភិវឌ្ឍន៍ឱ្យទៅជាមហាវិថីឈ្នះ-ឈ្នះ ហើយផ្ទៃបឹងចំនួន២០ ហិចតា បច្ចុប្បន្នកំពុងត្រូវបានចាក់លុប ដើម្បីបង្កើតជាផ្សារបន្លែធំមួយសម្រាប់ផ្គត់ផ្គង់នៅក្នុងរាជធានីភ្នំពេញ។[២៤] តម្លៃដីធ្លីនៅតំបន់នោះ បានហក់ឡើងខ្ពស់ នាប៉ុន្មានឆ្នាំចុងក្រោយនេះ[២៥] ដោយកើនឡើងដល់២៧% ចាប់ពីខែមករា ដល់ ខែមិថុនា ឆ្នាំ២០១៩។ ស្ថានភាពនេះ ធ្វើឱ្យសហគមន៍ក្នុងតំបន់នោះ ដែលទទួលព័ត៌មានពីខាងសាលារាជធានីភ្នំពេញថា ពួកគេកំពុងរស់នៅលើដីសាធារណៈរបស់រដ្ឋមានការព្រួយបារម្ភអំពីសុវត្ថិភាពដី និងផ្ទះសម្បែងរបស់ពួកគេ។ ហេតុដូចនេះហើយ ស្ថានភាពនេះ បានរម្លឹកអ្នកទាំងនោះថា ពួកគេមិនមានការការពារផ្នែកច្បាប់ពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំនៅថ្ងៃអនាគតនោះទេ។

ការកើនឡើងនូវតម្លៃដីធ្លី ការអភិវឌ្ឍផ្លូវថ្មីៗ និងទីផ្សារនៅក្នុងតំបន់នោះ ក៏ដូចជាសញ្ញានៃការបណ្តេញចេញគឺជាភស្តុតាងច្បាស់លាស់មួយនៃផែនការសម្រាប់តំបន់នោះ ដែលកំពុងត្រូវបានគេអនុវត្ត។ កង្វះខាតព័ត៌មានឱ្យគ្រប់ជ្រុងជ្រោយ បង្កឱ្យកាន់តែមានការព្រួយបារម្ភសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ ដែលអ្នកទាំងនោះ មិនទាន់មានប័ណ្ណកម្មសិទ្ធិដីធ្លី ហើយបង្កជាឱកាសដល់ការរំលោភយកដីធ្លី និងការលក់ដីដែលធ្វើឡើងដោយអ្នកខាងក្នុងស្ថានប័នរដ្ឋដែលដឹងអំពីផែនការអភិវឌ្ឍន៍នៅតំបន់នោះ។



**អ្នកនេសាទបេះផ្កាឈូក (ដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩ )**

[២៤] អនុក្រឹត្យលេខ ១៤៧ (ឆ្នាំ២០១៨) ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ)ស្ថិតនៅក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

[២៥] កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៩ <https://www.phnompenhpost.com/post-property/land-prices-three-capital-districts-see-sharp-increase>.




រូបភាពទី ៧៖ ផែនទីតំបន់ការពារទឹកជំនន់ បឹងតាមោក (ដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

## តំបន់ដីសើមបឹងទំពុន ឬជើងឯក

**ផ្ទៃបឹង៖** តំបន់ដីសើមសរុប ២,៨៥០ ហិចតា (មិនទាន់វាស់វែងតាមច្បាប់)១០៧ ហិចតា (វាស់វែងតាមច្បាប់[២៦])

**ចំនួនប្រជាពលរដ្ឋ(ប្រឈមនឹងការបណ្តេញចេញ ឬបាត់បង់របរចិញ្ចឹមជីវិត)៖** > ១,000 គ្រួសារអាចបាត់បង់របរចិញ្ចឹមជីវិត។ មួយចំនួនអាចប្រឈមនឹងការបណ្តេញចេញ។

**សារៈសំខាន់ផ្នែកបរិស្ថាន៖** ការពារពីទឹកជំនន់ តំបន់ប្រព្រឹត្តកម្មទឹកកខ្វក់តាមធម្មជាតិ ផ្តល់ភាពត្រជាក់ដល់បរិយាកាស តំបន់ពណ៌បៃតង កន្លែងពងរបស់ត្រីដែលផ្លាស់ទីពីទន្លេបាសាក់។




តំបន់ដីសើមបឹងទំពុន ឬជើងឯកនៅមិនទាន់មានការវាស់វែងព្រំប្រទល់ត្រឹមត្រូវនោះទេ ប៉ុន្តែវាស្ថិតនៅភាគខាងត្បូងរាជធានីភ្នំពេញ ដោយលាតសន្ធឹងគ្របដណ្តប់ដោយបឹង ស្ទឹង តំបន់ទំនាបលិចទឹក ជាច្រើនកន្លែង ដែលកន្លែងទាំងនោះ ត្រូវបានប្រជាពលរដ្ឋរស់នៅ និងប្រើប្រាស់តាំងពីការដួលរលំនៃរបបខ្មែរក្រហម

---

[២៦] អនុក្រឹត្យលេខ ១៤៨ ស្តីពីការកែសម្រួលផ្ទៃបឹងជើងឯក ស្ថិតនៅក្នុងខណ្ឌមានជ័យ និងដង្កោ នៃរាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ ខេត្តកណ្តាល ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៨

## ការប្រើប្រាស់ដោយប្រជាពលរដ្ឋ

សហគមន៍ជាច្រើនប្រើប្រាស់បឹងនេះ សម្រាប់ដាំដុះដំណាំលើទឹក ដូចជាកញ្ឆែត និងត្រកួន។ ប្រជាពលរដ្ឋជាច្រើនគ្រួសារអាចរកប្រាក់ចំណូលចន្លោះពី ៤០០,០០០រៀល (ប្រហែល១០០ដុល្លារអាមេរិក) ទៅ ៨០០,០០០ រៀល (ប្រហែល២០០ដុល្លារអាមេរិក) ក្នុងមួយខែ ពីដំណាំលើផ្ទៃទឹកក្នុងមួយហិចតា។ លើសពីនេះ ដីក្នុងតំបន់ដីសើមដែលលិចទឹកម្តងម្កាលផ្តល់នូវជីជាតិសម្រាប់ការធ្វើកសិកម្មនៅក្នុងសហគមន៍។ សហគមន៍នេសាទជាច្រើនរស់នៅតាមដងស្ទឹង នៅក្នុងតំបន់ដីសើម ដោយរកត្រីទាំងនៅក្នុងបឹង និងស្ទឹង។



ដំណាំលើផ្ទៃទឹកជាច្រើនជួរ ដែលជួយបន្សុទ្ធទឹកកខ្វក់ក្នុងរាជធានីភ្នំពេញ (ដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

| ប្រភេទត្រី | តម្លៃក្នុងមួយគីឡូក្រាម |
|---|---|
| ត្រីកំភ្លាញ | ៧.000 រៀល |
| ត្រីឆ្លាំង | ១.២00 រៀល |
| ត្រីឆ្ពួញ | ១0.000 រៀល |
| ត្រីរ៉ស់ | ១៦.000 រៀល |

## សារៈសំខាន់ផ្នែកបរិស្ថាន

តំបន់ដីសើមបឹងទំពុន ឬជើងឯក មានសារៈសំខាន់នៅក្នុងការប្រព្រឹត្តកម្មទឹកកខ្វក់ហូរចេញពីរាជធានីភ្នំពេញ និងការពារពីទឹកជំនន់ទាំងនៅភាគកណ្តាល និងភាគខាងត្បូងនៃទីក្រុង ដែលជាប់ព្រំប្រទល់នឹងទីក្រុងតាខ្មៅ។

បឹងនេះ ដើរតួនាទីជាអាងប្រព្រឹត្តកម្មទឹកបែបធម្មជាតិដែលមានប្រសិទ្ធភាពមធ្យម ដោយការប្រើប្រាស់រុក្ខជាតិនានានៅក្នុងផ្ទៃបឹង ដូចជាកញ្ឆែត និងត្រកួន ដែលរុក្ខជាតិទាំងពីរនេះដាំដោយកសិករក្នុងតំបន់ និងអាចជួយសម្អាតសារធាតុពុលចេញពីក្នុងទឹក។[២៧] នៅពេលដែលទឹកហូរចេញពីរាជធានីភ្នំពេញ ដូចជាទឹកលូកខ្វក់តាមរយៈប្រឡាយចំនួនបីធំៗ តំបន់ដីសើមនៅក្នុងតំបន់នោះ នឹងជារបាំងធម្មជាតិមួយ ការពារមិនឱ្យសារធាតុពុលហូរចូលទៅក្នុងទន្លេបាសាក់។

មានផែនការបច្ចុប្បន្នជាច្រើន សម្រាប់រោងចក្រប្រព្រឹត្តកម្មទឹក ហើយរំពឹងទុកថានឹងដំណើរការដោយមានការផ្តល់ជាជំនួយទាំងហិរញ្ញវត្ថុ និងបច្ចេកទេសពីអ្នកជំនាញជនជាតិជប៉ុនរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)[២៨]។

ជិត ៧0ភាគរយនៃទឹកភ្លៀង និងទឹកកខ្វក់ចេញពីរាជធានីភ្នំពេញ ហូរចូលទៅក្នុងតំបន់ដីសើមបឹងទំពុន ឬជើងឯក។[២៩]

យោងតាមរបាយការណ៍មួយ ដែលត្រូវបានធ្វើឡើងដោយមានការសហការរវាងសាលារាជធានីភ្នំពេញ ជាមួយនឹងសាលាក្រុងប៉ារីស ការបាត់បង់តំបន់ដីសើមបឹងទំពុន ឬបឹងជើងឯកនឹងធ្វើឱ្យទឹកកខ្វក់ចំនួន ២,៥ ទៅ ៣លានម៉ែត្រគូប នឹងត្រូវរកកន្លែងផ្សេង ដើម្បីធ្វើប្រព្រឹត្តិកម្ម[៣០] ដែលអាចនឹងបណ្តាលឱ្យជន់លិចផ្នែកផ្សេងក្នុងទីក្រុង ឬលិចភាគខាងក្រោម និងទីក្រុងតាខ្មៅ ឬលិចទាំងពីរផ្នែក។ ការចាក់ដីខ្សាច់ បច្ចុប្បន្នកំពុងបន្តសកម្មភាពនៅក្នុងតំបន់នោះ។

---

[២៧] Irvine et al, ២០១៥ "ការអនុវត្ត PCSWMM ដើម្បីវាយតម្លៃទិដ្ឋភាពការប្រព្រឹត្តកម្មទឹកកខ្វក់ និងទឹកជំនន់ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា៖ ឧបករណ៍មួយ ដើម្បីគាំទ្រការធ្វើផែនការទីក្រុងអេកូឡូស៊ី" ទិនានុប្បវត្តិគំរូនៃការគ្រប់គ្រងទឹក V ២៣

[២៨] អង្គការចៃកា (JICA) ២០១៩ "ការរៀបចំរបាយការណ៍ស្ទាបស្ទង់មតិ ស្តីពីគម្រោងប្រព័ន្ធអភិវឌ្ឍន៍ទឹកកខ្វក់នៅក្នុងរាជធានីភ្នំពេញ នៃប្រទេសកម្ពុជា"

[២៩] Ville de Paris និងសាលារាជធានីភ្នំពេញ (ឆ្នាំ២០១៨) សៀវភៅអំពីការពង្រីក និងការផ្លាស់ប្តូរនៃរាជធានីភ្នំពេញ

[៣០] ដូចខាងលើ



បុរសម្នាក់បង់សំណាញ់នៅបឹងតាមោក (ដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

## ៥. សេចក្តីសន្និដ្ឋាន

បឹង និងតំបន់ដីសើមជាច្រើនត្រូវបានបាត់បង់ ដោយភាគច្រើនបណ្តាលមកពីតម្រូវការផ្នែកអចលនវត្ថុរបស់ម្ចាស់គម្រោងសាងសង់បុរី និងទីក្រុងរណប។ បឹងនៅក្នុងទីក្រុងបច្ចុប្បន្ននេះត្រូវបានបាត់បង់អស់ មានតែបឹងសំរោង និងបឹងតាមោកប៉ុណ្ណោះដែលនៅសល់ ដោយជាង ៥០ភាគរយ នៃទំហំបឹងទាំងពីរនេះនឹងមិនទាន់ត្រូវបានគេប៉ះពាល់នៅឡើយទេ។

តំបន់ដីសើមជាច្រើនប្រឈមមុខនឹងអនាគតដែលមិនច្បាស់លាស់ ហើយជាង ៤០ភាគរយនៃតំបន់ដីសើម បច្ចុប្បន្នត្រូវបានបំផ្លិចបំផ្លាញ និងស្ថិតក្នុងបញ្ជីដែលត្រូវបាត់បង់។ មូលហេតុចម្បងៗនៃការបាត់បង់បឹង និងតំបន់ដីសើម ពោលគឺការបង្កើតអចលនទ្រព្យ ហើយជាញឹកញាប់ជាគម្រោងសាងសង់លំនៅឋានតម្លៃខ្ពស់ដែលមិនផ្តល់ជម្រើសផ្នែកលំនៅឋានសម្រាប់ប្រជាពលរដ្ឋក្រីក្របាននោះទេ។

ផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាននៃការបាត់បង់ទាំងនេះបាននឹងបន្តមានឥទ្ធិពលដែលជម្រុញឱ្យមានការបណ្តេញចេញពីលំនៅឋាន ការបាត់បង់ជីវភាព ការកើនឡើងនូវកម្រិតទឹកជំនន់ ការបំពុលបរិស្ថាន និងការបាត់បង់ជីវចម្រុះដែលអាចនឹងកើតមានប្រសិនបើបញ្ហានេះនៅតែបន្តមាន។

## ៦. អនុសាសន៍

ដោយផ្អែកលើការរកឃើញ របាយការណ៍នេះសូមផ្តល់អនុសាសន៍មួយចំនួន ដូចខាងក្រោម៖

១. សូមរាជរដ្ឋាភិបាលបង្ហាញជាសាធារណៈនូវបញ្ជីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅលើប្រព័ន្ធអ៊ិនធឺណេត។

២. ធ្វើការស្រាវជ្រាវបន្ថែមទៅលើផលប៉ះពាល់នៃការបាត់បង់បឹង និងតំបន់ដីសើមចំពោះរាជធានីភ្នំពេញ។

៣. ការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថានគួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ស្វែងរកបានតាមអ៊ិនធឺណេតដើម្បីអាចពិនិត្យមើលបាន និងបង្កើនតម្លាភាព។

៤. ប្រជាពលរដ្ឋជាច្រើនដែលទទួលបានផលប្រយោជន៍ពីបឹង គួរត្រូវបានអញ្ជើញជាដៃគូរក្នុងការប្រឹក្សាយោបល់ជាមួយរាជរដ្ឋាភិបាល។

៥. បឹង និងតំបន់ដីសើមសំខាន់ៗ ដូចជាបឹងតាមោក និងតំបន់ដីសើមបឹងទំពុន ឬជើងឯក គួរត្រូវបានអភិរក្សក្រោមច្បាប់ពិសេសដែលមានការការពារយ៉ាងតឹងរ៉ឹង ចំពោះការអភិវឌ្ឍ និងការធ្វើឱ្យខូចខាតណាមួយដោយសារការការពារបច្ចុប្បន្ន ក្រោមច្បាប់ភូមិបាលនៅមិនទាន់គ្រប់គ្រាន់នោះទេ ដែលនេះអាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ប្រទេសជាតិ។



សមាគមធាងត្នោត

Sahmakum Teang Tnaut- a Cambodian Urban NGO


ទូរសព្ទ៖ 023 555 1964

គេហទំព័រ៖ http://teangtnaut.org/

សំឡេងទីក្រុង៖ https://urbanvoicecambodia.net/

ហ្វេសប៊ុក៖ https://www.facebook.com/teangtnaut/